# ក្រមសីលធម៌សម្រាប់មន្ត្រី ដែលធ្វើការនៅមណ្ឌលចត្តាឡីស័ក

បុគ្គលិក និងអ្នកផ្តល់សេវាទាំងអស់ រួមទាំងអ្នកការពារសន្តិសុខ អ្នកស្ម័គ្រចិត្ត ដែលកំពុងដំណើរការមណ្ឌលចត្តាឡីស័ក ត្រូវធានាសេវាប្រកបដោយសីលធម៌វិជ្ជាជីវៈ គោរព គាំពារ ការពារសេចក្តីថ្លៃថ្នូរ ថែក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប ទោះបីកំពុងបំពេញ ឬសំរាកពីភារកិច្ច។ គោលការណ៍ដែលត្រូវប្រកាន់ខ្ជាប់៖

១. ត្រូវដឹងថា អ្នកជាប់ចត្តឡីសក្តិ៍ មិនមែនជាអ្នកដែលគេដកហូតសេរីភាពទេ។

២. ទទួលការបណ្តុះបណ្តាលពីវីរុសកូវីដ-១៩ និងការពិនិត្យតាមដានការអនុវត្តវិធានការការពារខ្លួន។

៣. យល់ដឹងពីយេនឌ័រដែលទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងសេវាកម្មបញ្ជូនសម្រាប់ជនរងគ្រោះ។

៤. ស្វែងយល់ពីស្ថានភាពងាយរងគ្រោះ និងរងគ្រោះជាក់លាក់របស់កុមារៈ កុមាររអាចរស់នៅតាមផ្លូវ គ្មានក្រុមគ្រួសារមើលថែ រងនូវអំពើហិង្សា និងការរំលោភបំពាននៅផ្ទះជាដើម។

៥. ធានាឱ្យមានការផ្តល់ជំនួយសមស្រប ប្រកបដោយសុវត្ថិភាព ការគោរពសេចក្តីថ្លៃថ្នូរ និងសេវាស្មើភាពគ្នារវាងស្ត្រី បុរស ក្មេងស្រី និងកត់ត្រាទិន្នន័យទៅតាម អាយុ និងភេទ។

៦. រាយការណ៍ទៅកាន់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ដែលជាជនបង្គោល អំពីករណីកុមារដែលបំបែកពីគ្រួសារ ឬមិនមានឪពុកម្តាយ ឬគ្មានអ្នកមើលថែ ដើម្បីទទួលបានការគាំទ្រសេវាសង្គម។

៧. អំពើហិង្សាគ្រប់រូបភាពក្នុងទីចត្តាឡីស័កត្រូវហាមឃាត់។ ការកែប្រែអាកប្បកិរិយាមនុស្ស គួរធ្វើឡើងតាមការអប់រំបែបចិត្តសាស្ត្រ និងការបញ្ច្រាបការយល់ដឹង។

៨. ហាមឃាត់ដាច់ខាត និងជាទង្វើខុសច្បាប់ គ្រប់ទម្រង់នៃការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងរាល់ការទទួលយកសាគុណជាថ្នូរនឹងសេវា ឬសកម្មភាពណាមួយក្នុងមណ្ឌលចត្តាឡីស័ក ។

៩. មិនត្រូវលេបខាយផ្លូវភេទជាមួយបុគ្គលណាម្នាក់ ដែលកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័ក។ សកម្មភាពផ្លូវភេទជាមួយកុមារ ត្រូវបានហាមឃាត់ដោយច្បាប់។

១០. ត្រូវបង្កើតយន្តការរាយកាណ៍ ដោយចាត់មន្ត្រីបង្គោលទទួលបន្ទុក រាយការណ៍ករណីសង្ស័យ ឬការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន និងត្រូវបញ្ជូនជនរងគ្រោះបន្តទៅរកសេវាថែទាំសុខភាព និងសេវាកម្មសង្គមឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។

១១. ត្រូវកំណត់អត្តសញ្ញាណ ស្ត្រី កុមារ ជនត្រូវការជំនួយផ្នែកសុខភាពផ្លូវចិត្ត រួមទាំងជនរងគ្រោះដោយការរំលោភបំពាន ដោយសម្របសម្រួលជាមួយអ្នកផ្តល់សេវាជួរមុខ (សេវាសុខភាព / សង្គម) ដើម្បីគាំទ្រ និងបញ្ជូនពួកគេបន្តទៅតាមនីតិវិធីដែលមានស្រាប់។

១២. មន្ត្រីគ្រប់គ្រងនៅគ្រប់កម្រិត ត្រូវធានាការអនុវត្តតាម ផ្តល់ការគាំទ្រ និងបង្កើតនូវបរិយាកាសអនុវត្តក្រមសីលធម៌នេះ។

១៣. ត្រូវចងក្រងជាឯកសាររក្សាទុក និងធានាការសម្ងាត់នូវព័ត៌មានស្តីពីការគ្រប់គ្រងករណី។

**ការបំពានក្រមសីលធម៌នេះ នឹងត្រូវចាត់ទុកថាជាការប្រព្រឹត្តមិនត្រឹមត្រូវ និងត្រូវស៊ើបអង្កេតដើម្បីចាត់ការតាមច្បាប់។**

សហការជាមួយ៖ ក្រសួងសុខាភិបាល

គាំទ្រដោយ៖ USAID FROM THE AMERICAN PEOPLE · unicef for every child · UN WOMEN · UNFPA · UNITED NATIONS HUMAN RIGHTS · Save the Children